# Vacancy Announcement

FTB
ធនាគារពាណិជ្ជកម្មក្រៅប្រទេស នៃកម្ពុជា
Foreign Trade Bank of Cambodia

## ដំណឹងជ្រើសរើសបុគ្គលិក

ធនាគារពាណិជ្ជកម្មក្រៅប្រទេស នៃកម្ពុជា (FTB) គឺជាធនាគារពាណិជ្ជក្នុងស្រុកទី១ នៅកម្ពុជាដែលទទួលបានការទុកចិត្តចាប់តាំងពីឆ្នាំ១៩៧៩ ។ ធនាគារ FTB បានផ្តល់ជូនអតិថិជននូវសេវាហិរញ្ញវត្ថុប្រកបដោយភាពជឿទុកចិត្ត និងសុវត្ថិភាពខ្ពស់ក្នុងធុរកិច្ចរបស់ខ្លួន ។ ផ្អែកលើចក្ខុវិស័យ ជាធនាគារពាណិជ្ជដែលមានការពេញចិត្តជាងគេក្នុងព្រះរាជាណាចក្រកម្ពុជា ធនាគារ FTB ប្តេជ្ញាបន្តគាំទ្រធុរកិច្ចរបស់អតិថិជនឲ្យកាន់តែរីកចម្រើនលូតលាស់ និងផ្តល់ជូនគ្រប់បុគ្គលិកនូវឱកាសអាជីពការងារ ដែលមានស្ថិរភាពយូរអង្វែងផងដែរ ។ ធនាគារកំពុងបន្តពង្រីកនូវវិសាលភាពប្រតិបត្តិការរបស់ខ្លួន និងពង្រឹងសមត្ថភាពបុគ្គលិកដើម្បីជួយទ្រទ្រង់នូវការរីកចម្រើនប្រកបដោយចីរភាពយូរអង្វែង។ ទន្ទឹមនឹងការពង្រីកប្រតិបត្តិការនេះធនាគារយើងខ្ញុំ កំពុងស្វែងរកនូវបេក្ខភាពដែលមានគុណវុឌ្ឍិ និងឆន្ទៈខ្ពស់ ដើម្បីចូលរួមជាមួយធនាគារ FTB "**និយោជកដ៏ប្រសើរនិងឈានមុខ**" សម្រាប់មុខងារខាងក្រោម៖

### អ្នកបើកបររថយន្ត (ចំនួន ០២ នាក់ បម្រើការនៅភ្នំពេញ)

បម្រើការងារនៅភ្នំពេញ និងអាចធ្វើដំណើរចុះតាមបណ្តាសាខាខេត្ត-ក្រុង។ អ្នកបើកបររថយន្ត ត្រូវបើកបរជូននិយោជិត បុគ្គលិក មន្ត្រី និងថ្នាក់ដឹកនាំធនាគារ ប្រកបដោយការប្រុងប្រយ័ត្ន សន្តិសុខ សុវត្ថិភាព និងការទទួលខុសត្រូវខ្ពស់បំផុត។

### កិច្ចការចម្បងៗ និងការទទួលខុសត្រូវ

- ដឹកជញ្ជូនភ្ញៀវ-អតិថិជនខាងក្នុង ឧបករណ៍-សម្ភារៈ និងបរិក្ខាររបស់ធនាគារឱ្យដល់គោលដៅ ប្រកបដោយសុវត្ថិភាព
- ថែទាំរថយន្តឱ្យបានល្អប្រសើរ ដោយត្រូវថែទាំរថយន្តទាំងលើបច្ចេកទេស និងសោភ័ណភាពជាសប្រចាំថ្ងៃ តាមលក្ខណៈបច្ចេកទេស
- ត្រូវត្រួតពិនិត្យជាប្រចាំ តាមលក្ខណៈបច្ចេកទេសលើប្រេង ភ្លើង ទឹក ម៉ាស៊ីនត្រជាក់ កង្ហា ខ្សែក្រវ៉ាត់ កង់ និងឧបករណ៍ផ្សេងៗពាក់ព័ន្ធប្រព័ន្ធដំណើរការរថយន្ត ដើម្បីធានាបាននូវសន្តិសុខ និងសុវត្ថិភាពខ្ពស់ដល់ការបើកបរ
- ផ្តល់ដំណឹងដល់អ្នកគ្រប់គ្រងពេលដែលរថយន្តដល់ពេលកំណត់ត្រូវដែក និងពេលឡានត្រូវជួសជុល/ថែទាំ
- ធានាបានលើការបើកបររថយន្ត ត្រូវអនុវត្តឱ្យបានត្រឹមត្រូវទៅតាមច្បាប់ចរាចរណ៍នៃព្រះរាជាណាចក្រកម្ពុជា
- ជួយការងារបន្ទាប់បន្សំផ្សេងៗទៀតដូចជាការលើកដាក់ឧបករណ៍-សម្ភារៈ បរិក្ខារនៅពេលដែលមានការពឹងពាក់ពីបុគ្គលិក ឬអ្នកធ្វើដំណើរជាមួយ
- ធ្វើកិច្ចការទៅតាមតម្រូវការរបស់អ្នកគ្រប់គ្រង

### លក្ខណសម្បត្តិ និងបទពិសោធន៍

- យ៉ាងតិចមានសញ្ញាបត្របឋមភូមិ (សញ្ញាបត្រថ្នាក់ទី ៩ (ជាប់ឌីប្លូម) )
- ជានីតិជន ដែលមានសញ្ជាតិជាខ្មែរ និងចេះអាន សរសេរ ភាសាខ្មែរបានល្អ ។ ចេះភាសាអង់គ្លេស ត្រូវបានលើកទឹកចិត្ត
- មានបទពិសោធន៍យ៉ាងតិច ២ឆ្នាំ ពាក់ព័ន្ធលើការបើកបររថយន្ត (ទាំងលេខដៃ និងអូតូ)
- ត្រូវមានប័ណ្ណបើកបររថយន្តដែលមានសុពលភាពស្របច្បាប់ត្រឹមត្រូវ
- មានលក្ខណសម្បត្តិក្នុងការប្រាស្រ័យទាក់ទងល្អ រួសរាយ រាក់ទាក់ និងមានឥរិយាបថចេះបម្រើអតិថិជន
- មានភាពស្មោះត្រង់ សុចរិតភាព អត់ធ្មត់ និងសកម្មលើការងារ
- ចេះដោះស្រាយបញ្ហា និងអាចជួសជុលរថយន្តពេលដែលខូច ឬក៏មានបញ្ហាអសកម្មបន្តិចបន្តួចនៅតាមផ្លូវ
- យល់ដឹងពីច្បាប់ចរាចរណ៍ និងបទបញ្ញាផ្សេងៗសម្រាប់ចរាចរណ៍ផ្លូវគោក ច្បាស់លាស់ និងត្រឹមត្រូវ

### របៀបដាក់ពាក្យ

បេក្ខជនដែលមានចំណាប់អារម្មណ៍ សូមអញ្ជើញផ្ញើប្រវត្តិរូបសង្ខេប (មានបិទរូបថត) ជាមួយលិខិតអមជាភាសាខ្មែរ/អង់គ្លេសមកធនាគារតាមរយៈអ៊ីម៉ែល: HR@ftbbank.com ឬការិយាល័យកណ្តាល ស្ថិតនៅអគារលេខ ៣៣C-D ផ្លូវលេខ ១៦៩ សង្កាត់វាលវង់ ខណ្ឌ ៧មករា រាជធានីភ្នំពេញ ឬតាមសាខាណាមួយ របស់ធនាគារពាណិជ្ជកម្មក្រៅប្រទេស នៃកម្ពុជា ។ មានតែបេក្ខជនដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់នឹងត្រូវបានជាប់ក្នុងបញ្ជីសម្រាំង និងត្រូវបានទូរស័ព្ទអញ្ជើញឲ្យមកចូលសម្ភាសន៍ ។
ព័ត៌មានបន្ថែមសូមទំនាក់ទំនងមកកាន់លេខទូរសព្ទ: ០៨១ ៦៦៦ ៥៩៧/០៨១ ៦៦៦ ៥៣៥

☎ : 023 862 111
E-mail: info@ftbbank.com
www.ftbbank.com
f : www.facebook.com/ftbcambodia

វិនិយោគដើម្បីអនាគត
Investing in the future